វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA

# ឯកសារស្រាវជ្រាវសង្ខេប

## គណៈកម្មការទី៧ នៃព្រឹទ្ធសភា

# បញ្ហាប្រឈមក្នុងការអប់រំថ្នាក់មូលដ្ឋាន នៅខេត្តព្រះវិហារ ឧត្តរមានជ័យ និងបន្ទាយមានជ័យ

ខែកក្កដា ឆ្នាំ២០១៧

អ្នកស្រាវជ្រាវ៖ លោក ឆន ប៉ូល
លោកស្រី គឹម កែវធីតា

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជាតាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិកាសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាឲ្យបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៧ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា


១. សេចក្តីផ្តើម ........ 1
២. ទិដ្ឋភាពទូទៅ និងវឌ្ឍនភាពនៃការអប់រំមូលដ្ឋាន ........ 1
៣. វឌ្ឍនភាពនៃការអប់រំមូលដ្ឋាននៅខេត្ត ឧត្តរមានជ័យ ព្រះវិហារ និងបន្ទាយមានជ័យ ........ 3
៤. បញ្ហាប្រឈម ........ 4
*បញ្ហាប្រឈមនៅសាលារៀន* ........ 4
*បញ្ហាប្រឈមទាក់ទងនឹងគ្រូបង្រៀន* ........ 5
៥. ទិសដៅគោលនយោបាយ ........ 6
៦. ការមើល ឆ្ពោះទៅមុខ ........ 6
៧. សេចក្តីសន្និដ្ឋាន ........ 9
ឯកសារយោង ........ 10

## ១. សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចប់ការអនុវត្តផែនការជាតិដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣ - ២០១៥ ហើយបានបន្តផ្តល់អាទិភាពទៅលើការកែលម្អគុណភាពអប់រំថ្នាក់មូលដ្ឋាន ដោយរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដោយមានភ្ជាប់ទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព[1]។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ មានគោលដៅពង្រីក និងកែលម្អការអប់រំមូលដ្ឋាន និងធានាឲ្យមានការទទួលបានការអប់រំថ្នាក់មូលដ្ឋានសម្រាប់ កុមារី កុមារពិការ និងជនជាតិភាគតិច[2]។ ទោះបីជាមានវឌ្ឍនភាពគួរឲ្យកត់សម្គាល់នៅថ្នាក់ជាតិក៏ដោយ ក៏ខេត្តមួយចំនួននៅមានការយឺតយ៉ាវខ្លះ។

អត្ថបទស្រាវជ្រាវសង្ខេបនេះនឹង (១) បង្ហាញយ៉ាងសង្ខេបពីសមិទ្ធិផលនៃការអប់រំថ្នាក់មូលដ្ឋាននៅកម្រិតថ្នាក់ជាតិ និងនៅខេត្ត ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ (២) ពិនិត្យមើលការប្រឈមនៃកិច្ចខិតខំប្រឹងប្រែងដើម្បីកែលម្អការអប់រំមូលដ្ឋាន និង (៣) បង្ហាញពីតួនាទីរបស់ឃុំ សង្កាត់ ទាក់ទងនឹងការកែលម្អគុណភាពការអប់រំមូលដ្ឋាន។

## ២. ទិដ្ឋភាពទូទៅ និងវឌ្ឍនភាពនៃការអប់រំមូលដ្ឋាន

ដើម្បីកែលម្អវិស័យអប់រំ ទាំងគុណភាព និងបរិមាណ រដ្ឋាភិបាលបានអនុវត្តគោលនយោបានមួយចំនួនដូចជាកម្មវិធីទ្រទ្រង់វិស័យអប់រំ ឆ្នាំ ២០០១-២០០៥ ផែនការជាតិដើម្បីការអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០០៣ - ២០១៥ ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំ ឆ្នាំ ២០០៦ - ២០១០ ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំ ឆ្នាំ ២០០៩ - ២០១៣ និង ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំ ឆ្នាំ ២០១៤ - ២០១៨ ដោយមានភ្ជាប់ទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព។

តារាងទី ១៖ សូចនាករទាក់ទងនឹងការអប់រំបឋមសិក្សា (ថ្នាក់ជាតិ)

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ |
|---|---|---|---|---|---|---|
| អត្រាពិតចូលរៀនថ្មី | ៧៦,៤០ | ៩៤,៣០ | ៩៨,១០ | ៩៤,៥០ | ៩៥,៩០ | ៩៥,១០ |
| អត្រាពិតនៃការសិក្សា | ៨៣,៨០ | ៩៧,០០ | ៩៨,២០ | ៩៧,៩០ | ៩៨,៤០ | ៩៧,៧០ |
| អត្រាបោះបង់ការសិក្សា | - | ១០,៥០ | ៨,៣០ | ៦,២០ | ៤,៦០ | - |
| អត្រាបញ្ចប់ការសិក្សា | ៤៦,៨០ (២០០៤-២០០៥) | ៨៧,៣៥ | ៨៨,៩៤ | ៨៤,១០ | ៨០,៦០ | ៧៩,៩០ |
| អត្រាត្រួតថ្នាក់ | ៤២,៩០ (២០០៥-២០០៦) | ៤,៨០ | ៥,១០ | ៦,៧០ | ៦,៦០ | - |
| អត្រាឆ្លងភូមិសិក្សា | ៨២,៦០ | ៧៦,៨០ | ៧៦,៨០ | ៧៨,៧០ | ៨២,១០ | ៨៥,៥០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

តារាងទី ១ បង្ហាញថា កម្ពុជាមានវឌ្ឍនភាពដ៏ធំធេងក្នុងការអប់រំបឋមសិក្សា។ អត្រាពិតចូលរៀនថ្មីបានកើនឡើងជាលំដាប់ពី ៨៣,៨០% នៅឆ្នាំ ២០០០ ដល់ ៩៧,៧០% នៅឆ្នាំ ២០១៦។ នេះមានន័យថា កុមារអាយុ ៦ឆ្នាំ ស្ទើរតែទាំងអស់ ត្រូវបានចុះឈ្មោះចូលរៀនថ្នាក់ទី១។ កុមារអាយុពី ៦ឆ្នាំ ដល់១១ឆ្នាំ ស្ទើរតែទាំងអស់ ត្រូវបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា។ សូចនាករផ្សេងៗទៀតក៏មានលក្ខណៈវិជ្ជមានដែរ។ អត្រាបញ្ចប់ការសិក្សា មានស្ថិរភាព និងអត្រាឆ្លងភូមិសិក្សាបានបន្តកើនឡើងពី ៨២,១០ ភាគរយ នៅឆ្នាំ ២០១៥ - ២០១៦ ដល់ ៨៥,៥% នៅឆ្នាំបន្ទាប់។ នេះមានន័យថា សិស្សតិចជាង១៥% មិនបានឆ្លងទៅរៀននៅមធ្យមសិក្សាបឋមភូមិទេ។

តារាងទី ២៖ សូចនាករទាក់ទងនឹងមធ្យមសិក្សាបឋមភូមិ (ថ្នាក់ជាតិ)

| សូចនាករ | ២០០០-២០០១ | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
|---|---|---|---|---|---|
| អត្រារួមនៃការសិក្សា | - | - | - | ៥៥,១០ | ៦៥,៥០ |
| អត្រាឡើងថ្នាក់ | - | ៧៧,៤០ | ៧៧,២០ | ៧៨,៦០ | ៨០,៦០ |
| អត្រាត្រួតថ្នាក់ | - | ១,៤០ | ១,៨០ | ២,២០ | ២,៥០ |
| អត្រាបោះបង់ការសិក្សា | - | ២១,២០ | ២១,០០ | ១៩,២០ | ១៧,០០ |
| អត្រាឆ្លងភូមិសិក្សា | ៦៣,០០ | ៦៩,១០ | ៧១,១០ | ៧២,៩០ | ៧៦,៦០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

បើយោងតាមតារាងទី ២ ខាងលើ មានវឌ្ឍនភាពនៃការអប់រំថ្នាក់មធ្យមសិក្សាបឋមភូមិ មានកម្រិតទាបជាងវឌ្ឍនភាពនៃការអប់រំថ្នាក់បឋមសិក្សា។ អត្រាឡើងថ្នាក់ និងអត្រាឆ្លងភូមិសិក្សាគឺ ៨០,៦០ ភាគរយ និង ៧៦,៦០ភាគរយ ដែលមានន័យថា ប្រហែល ២៣,៤០ភាគរយ នៃសិស្សមធ្យមសិក្សាបឋមភូមិ មិនបានឆ្លងទៅសិក្សានៅវិទ្យាល័យ។ អត្រាបោះបង់ការសិក្សានៅមានកម្រិតខ្ពស់ (១៧%) ហើយអត្រាឡើងថ្នាក់បានបន្តកើនឡើង ប៉ុន្តែនៅត្រឹម ៨០,៦០ភាគរយ នៅឆ្នាំសិក្សា ២០១៥ - ២០១៦។ នេះមានន័យថា សិស្សមធ្យមសិក្សាបឋមភូមិមិនបានឡើងថ្នាក់នៅឆ្នាំបន្ទាប់។ អត្រាឆ្លងភូមិសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ គឺ ៨៥,៥០ភាគរយ និង ៧៦,៦០ភាគរយ។ អត្រានេះ រួមនឹងអត្រាបោះបង់ការសិក្សាខ្ពស់ មានន័យថា មានកុមារមួយចំនួនមិនបានឆ្លងទៅរៀននៅវិទ្យាល័យទេ។

កម្រិតថ្នាក់ជាតិ កម្ពុជាបានសម្រេចនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ទាក់ទងនឹងសូចនាករខាងលើ។ លើសពីនេះទៀត ចំនួនសាលាបឋម និងសាលាមធ្យមសិក្សាបឋមភូមិបានកើនឡើងពី ៥.៨៣៥ ក្នុងឆ្នាំ ២០០០ ដល់ ៨.៣៣៦ នៅឆ្នាំ ២០១៥។ ចំនួនសិស្ស និងគ្រូបង្រៀន ក៏បានកើនឡើងដែរ។[3] ក្រៅពីគោលនយោបាយដែលបានលើកឡើងខាងលើ មានគោលនយោបាយផ្សេងទៀតត្រូវបានរៀបចំឡើង និងអនុវត្ត ដូចជា កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា គោលនយោបាយសាលាកុមារមេត្រី[4]។

## ៣. ចន្លោះនិន្នាការនៃការអប់រំមូលដ្ឋាននៅខេត្ត ឧត្តរមានជ័យ ព្រះវិហារ និងបន្ទាយមានជ័យ

បើប្រៀបធៀបទៅនឹងសូចនាករថ្នាក់ជាតិ អត្រាពិតនៃការសិក្សា និងអត្រាឡើងថ្នាក់នៃការអប់រំបឋមសិក្សា បានធ្លាក់ចុះជាលំដាប់នៅក្នុងខេត្តឧត្តរមានជ័យ និងព្រះវិហារ (សូមមើលតារាងទី ៣)។ ផ្ទុយទៅវិញ អត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់បានកើនឡើង (សូមមើលតារាងទី ៣)។

តារាងទី ៣៖ សូចនាករស្តីពីការអប់រំបឋមសិក្សានៅខេត្តឧត្តរមានជ័យ និងព្រះវិហារ

| សូចនាករ | ឧត្តរមានជ័យ | | | ព្រះវិហារ | | |
|---|---|---|---|---|---|---|
| | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| អត្រាពិតនៃការសិក្សា | ៩២,៥០ | ៨៧,៧០ | ៨៤,៣០ | ៩៦,៨ | ៩៥,៣០ | ៩៣,៦០ |
| អត្រាឡើងថ្នាក់ | ៨២,១០ | ៨២,១០ | ៨០,៦០ | ៨១,០០ | ៨១,០០ | ៧៨,៦០ |
| អត្រាត្រួតថ្នាក់ | ៥,៤០ | ៥,៤០ | ៩,២០ | ៨,៩០ | ៨,៩០ | ១២,១០ |
| អត្រាបោះបង់ការសិក្សា | ១២,៤០ | ១២,៤០ | ១០,២០ | ១០,១០ | ១០,១០ | ៩,៣០ |
| អត្រាឆ្លងភូមិសិក្សា | ៦៨,៣០ | ៦៩,០០ | ៧១,៤០ | ៦៣,០០ | ៧៧,៧០ | ៧៨,៩០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

តារាងទី ៤ បង្ហាញថា នៅខេត្តបន្ទាយមានជ័យ អត្រាឆ្លងភូមិសិក្សា និងអត្រាឡើងថ្នាក់មានកម្រិតទាបជាងថ្នាក់ជាតិបន្តិច។ ជាងនេះទៀត អត្រាបោះបង់ការសិក្សាខ្ពស់ជាងថ្នាក់ជាតិផងដែរ។ បើយោងតាមតារាងទី ៤ នេះ សិស្សចំនួន ៣៣ភាគរយ មិនបានឆ្លងភូមិសិក្សាទៅវិទ្យាល័យទេ ហើយអត្រាបោះបង់ការសិក្សាគឺ ២២,៦០ភាគរយ។ តួលេខនេះមានកម្រិតខ្ពស់បង្គួរ។

តារាងទី ៤៖ សូចនាករទាក់ទងនឹងមធ្យមសិក្សាបឋមភូមិនៅខេត្តបន្ទាយមានជ័យ

| សូចនាករ | បន្ទាយមានជ័យ | | |
|---|---|---|---|
| | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| អត្រាឡើងថ្នាក់ | ៧៤,២០ | ៧៤,២០ | ៧៥,៣០ |
| អត្រាត្រួតថ្នាក់ | ១,៧០ | ១,៧០ | ២,២០ |
| អត្រាបោះបង់ការសិក្សា | ២៤,០០ | ២៤,២០ | ២២,៦០ |
| អត្រាឆ្លងភូមិសិក្សា | ៦៥,១០ | ៦៣,០០ | ៦៧,០០ |

ប្រភព៖ ស្ថិតិ និងសូចនាករអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា

យន្តការគាំទ្រថ្នាក់មូលដ្ឋាន

យន្តការខាងក្រោមនេះត្រូវបានបង្កើតឡើង ដើម្បីជួយជម្រុញឲ្យការអប់រំនៅកម្រិតមូលដ្ឋានកាន់តែប្រសើរឡើង៖

- គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា តំណាងឲ្យសហគមន៍ក្នុងការសម្របសម្រួល និងការរៀបចំផែនការអភិវឌ្ឍន៍សាលា។ ក្នុងគណៈកម្មការ រួមមាន ប្រធាន អនុប្រធាន និងសមាជិកមួយចំនួន។ មេឃុំ គឺជាប្រធានកិត្តិយស[5]។
- គណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានបង្កើតឡើងនៅកម្រិតថ្នាក់ឃុំ និងមានមេឃុំជាប្រធាន។ គណៈកម្មការអប់រំសម្រាប់ទាំងអស់មានតួនាទីជានាថា កុមារទាំងអស់ត្រូវបានចុះឈ្មោះចូលរៀន និងគៀងគរការគាំទ្រពីដៃគូអភិវឌ្ឍន៍នៅក្នុងមូលដ្ឋានរបស់ពួកគេ។[6]
- ការិយាល័យអប់រំថ្នាក់ស្រុក មានតួនាទីត្រួតពិនិត្យផែនការអភិវឌ្ឍន៍សាលារៀន និងគាំទ្រដល់ដំណើរការសាលារៀន។ ការិយាល័យអប់រំស្រុកមាន ក្រុមបណ្តុះបណ្តាលនិង ពិនិត្យតាមដាន ដែលក្រុមនេះទទួលការបណ្តុះបណ្តាលពីក្រសួងអប់រំ ហើយមានតួនាទីបណ្តុះបណ្តាល និងពិនិត្យតាមដានគ្រូបង្រៀន និងរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាដែលត្រូវដោះស្រាយ។[1, 7]

ដូចនេះ យន្តការខាងលើនេះ បង្ហាញថា ថ្នាក់ដឹកនាំឃុំមានតួនាទីគាំទ្រគុណភាពអប់រំថ្នាក់មូលដ្ឋាននៅក្នុងឃុំ។ ពួកគេ ជួយជំរុញការចុះឈ្មោះចូលរៀន និងការចូលរួមរបស់សហគមន៍ និងចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។ ប៉ុន្តែបើទាក់ទងនឹងគុណភាពអប់រំវិញ គ្រូបង្រៀន និងសាលារៀនដើរតួនាទីយ៉ាងសំខាន់។[8] លើសពីនេះ ក្រុមបណ្តុះបណ្តាល និងពិនិត្យតាមដានថ្នាក់ស្រុក ជាតួអង្គសំខាន់ក្នុងការបណ្តុះបណ្តាលគ្រូ និងការពិនិត្យតាមដាន ដែលនឹងមានផលប៉ះពាល់ដោយផ្ទាល់ទៅលើគុណភាពអប់រំ។

## ៤. បញ្ហាប្រឈម

ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអប់រំថ្នាក់មូលដ្ឋានទាំងគុណភាព និងបរិមាណ រដ្ឋាភិបាលជួបប្រទះនូវបញ្ហាប្រឈមជាច្រើន។ បញ្ហាប្រឈមទាំងនេះរួមមាន កង្វះខាតគ្រូបង្រៀន និងអគារសិក្សា ហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធទឹក បន្ទប់ទឹក និងសមាមាត្រសិស្សធៀបនឹង គ្រូបង្រៀនខ្ពស់ បញ្ហាសិស្ស ភាពក្រីក្រ។ល។ ដោយបញ្ហាគ្រូ និងសាលារៀន ជាបញ្ហាចម្បងនៅក្នុងវិស័យអប់រំ ឯកសារស្រាវជ្រាវសង្ខេបនេះផ្តោតទៅលើបញ្ហាប្រឈមទាំងនេះ។

*បញ្ហាប្រឈមនៅសាលារៀន*

សាលារៀននៅប្រទេសកម្ពុជារៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងទទួលបានថវិកាចំនួនបួនដំណាក់កាលក្នុងមួយឆ្នាំ។[9] ថវិកាសាលារៀនអាចទទួលបានពី ១.០៦០.០០០រៀល ទៅ ២.៣៥០.០០០រៀល សម្រាប់សាលាបឋមសិក្សា និងពី ២៦៥.៨០០រៀល ទៅ ៤៩០.០០០រៀល សម្រាប់ថ្នាក់វិទ្យាល័យ ហើយថវិកាអាចរួមបញ្ចូលទាំងថវិកាទាក់ទងនឹងរដ្ឋបាល សម្ភារសិក្សា សម្ភារបង្រៀន ការជួសជុលតូចតាច វិក្កយបត្រ ទឹក និងភ្លើង។[9]

មានសាលារៀនជាង ៩០ភាគរយ បានរៀបចំផែនការអភិវឌ្ឍន៍សាលារៀនរបស់ពួកគេ និងបានដាក់សំណើសុំថវិកាបានទាន់ពេលវេលា។[9, 10] ការស្រាវជ្រាវមួយបានបង្ហាញថា មានសាលារៀន ចំនួន ៦៧ភាគរយ ជឿជាក់ថា ផែនការអភិវឌ្ឍន៍របស់ពួកគេមានលក្ខណៈសមស្រប ហើយមានសាលារៀនជាង ៧០ភាគរយ អនុវត្តផែនការអភិវឌ្ឍន៍បានតែជាង ៧០ភាគរយ នៃសកម្មភាពរបស់ពួកគេប៉ុណ្ណោះ។ [9] មានសាលារៀន ចំនួន ៨៥ភាគរយ បានចំណាយថវិការបស់ពួកគេច្រើនជាង ៥០ភាគរយ ខណៈពេលដែលមានសាលារៀន ចំនួន តែ១៥ភាគរយ ប៉ុណ្ណោះ អះអាងថាពួកគេត្រូវតែធ្វើការកែតម្រូវផែនការអភិវឌ្ឍន៍របស់ពួកគេ។

ទាក់ទងនឹងថវិកាសាលារៀន សាលារៀននៅតែជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដូចខាងក្រោម៖

- ទោះបីសាលារៀនអាចមានចំណូល និងការចូលរួមចំណែកពីសហគមន៍[3] ប៉ុន្តែថវិការបស់សាលាគឺតិចតួចបើប្រៀបធៀបទៅនឹងតម្រូវការហរិញ្ញវត្ថុសម្រាប់ការអភិវឌ្ឍសាលារៀន។
- ការបើកថវិកាសាលារៀនអាចត្រូវបានពន្យារពេល ដែលធ្វើឲ្យមានការពន្យារពេលក្នុងការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនផងដែរ។ ដូចដែលបានកត់សម្គាល់ខាងលើ មានសាលារៀនចំនួន ៨៥ ភាគរយ បានចំណាយច្រើនជាង ៥០ ភាគរយនៃថវិការបស់ពួកគេ ខណៈពេលដែលមានតែសាលារៀនចំនួន ១៥ ភាគរយប៉ុណ្ណោះ ចំណាយតិចជាង៥០ ភាគរយ។ វាមិនមានភាពច្បាស់លាស់នៅឡើយទេទាក់ទងទៅនឹងភាគរយរបស់សាលារៀនដែលបានចំណាយថវិកាទាំងអស់របស់ពួកគេនោះទេ។ ការសិក្សាមួយដែលបានធ្វើឡើងដោយភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NGO Education Partnership) នៅក្នុងខេត្តចំនួនប្រាំ បានបង្ហាញថា ជាមធ្យម សាលារៀនមួយចំនួនទទួលបានថវិកាប្រមាណជា ៦៥ ភាគរយ នៃសំណើថវិការបស់ពួកគេ ពីព្រោះ ជាមធ្យមសាលារៀនទទួលបានថវិកាតែ៣ ដំណាក់កាលនៃថវិកា ៤ដំណាក់កាលដែលពួកគេត្រូវទទួល។[10]
- បន្ទាត់ថវិកាមិនមានភាពបត់បែនគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការអភិវឌ្ឍន៍របស់សាលារៀននីមួយៗ ។
- នីតិវិធីហិរញ្ញវត្ថុ គឺមានភាពស្មុគស្មាញ ហើយត្រូវបានកែប្រែជាញឹកញាប់ ដែលបណ្តាលឲ្យមានការយល់ច្រឡំ។
- ថវិកាសាលារៀនមិនបានរួមបញ្ចូលថ្លៃធ្វើដំណើរនោះទេ ដែលបង្កជាបញ្ហាប្រឈមមួយចំនួនដល់សាលារៀន នៅតំបន់ជនបទដាច់ស្រយាល។

*<u>បញ្ហាប្រឈមទាក់ទងនឹងគ្រូបង្រៀន</u>*

- ថ្វីបើមានការកើនឡើងនៃចំនួនគ្រូបង្រៀននៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដែលពេលបច្ចុប្បន្ននេះមានចំនួន ៤៤.៨៨៤ នាក់ និង ៤០.៩២៤នាក់ [3] (នៅឆ្នាំ២០១៦) ក៏នៅតែមានការខ្វះខាតគ្រូ។ [4]
- ក្នុងចំណោមគ្រូបង្រៀននៅកម្រិតបឋមសិក្សាទាំងអស់ គ្រូបង្រៀនប្រហែលជា ៣០ ភាគរយ មានការអប់រំកម្រិតអនុវិទ្យាល័យ ឬក៏ទាបជាងអនុវិទ្យាល័យ។ ក្នុងចំណោមគ្រូថ្នាក់អនុវិទ្យាល័យទាំងអស់ គ្រូបង្រៀនប្រហែលជា ៥០ភាគរយ មានការអប់រំកម្រិតវិទ្យាល័យ ប្រហែលជា ១៤ ភាគរយ មានការ

អប់រំកម្រិតអនុវិទ្យាល័យ និង ០,៧០ភាគរយ មានកម្រិតអប់រំកម្រិតបឋមសិក្សា។ [3] ហេតុដូច្នេះហើយ ការអប់រំនិងវិធីសាស្រ្តបង្រៀនរបស់គ្រូបង្រៀនមួយចំនួននៅមានកម្រិត នៅឡើយ។[4]

## ៥. ទិសដៅគោលនយោបាយ

នៅក្នុងសន្និបាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ទិសដៅគោលនយោបាយជាច្រើនត្រូវបានកំណត់។ ឯកសារស្រាវជ្រាវសង្ខេបនេះ ជ្រើសរើសយកតែគោលនយោបាយណាដែលពាក់ព័ន្ធនឹងសាលារៀន គ្រូបង្រៀន និងកម្មវិធីសិក្សាប៉ុណ្ណោះ មកបង្ហាញ។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានស្នើដូចខាងក្រោម៖ លើកកម្ពស់ការប្រើប្រាស់ថវិកាតាមសាលារៀនប្រកបដោយប្រសិទ្ធភាព កែលម្អការចែកចាយសៀវភៅទៅតាមសាលារៀនយោងទៅតាមការផ្គត់ផ្គង់ និងតម្រូវការ ពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅសាលារៀន ពង្រឹងគណៈកម្មាធិការទ្រទ្រង់សាលារៀន កែលម្អកម្មវិធីសិក្សា ពង្រឹងការបណ្តុះបណ្តាលមុនពេល និងក្នុងពេលបម្រើការងាររបស់គ្រូបង្រៀន ហើយនិងរៀបចំឲ្យមានការធ្វើតេស្តវាយតម្លៃសិស្សជាលក្ខណអន្តរជាតិសម្រាប់ការអភិវឌ្ឍ។[4]

ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងថវិកាសាលារៀន កំណែទម្រង់វិស័យអប់រំនៅប្រទេសកម្ពុជា (សៀវភៅដែលនិពន្ធដោយឯកឧត្តម បណ្ឌិត ហង្ស ជួនណារុង) បានលើកឡើងថា នីតិវិធីហិរញ្ញវត្ថុគួរតែត្រូវបានសម្រួល [9] ។ ថ្លៃចំណាយផ្សេងៗទៀត ដូចជាការចំណាយលើការធ្វើដំណើរត្រូវអនុញ្ញាតនៅក្នុងថវិកាសាលារៀន ហើយបន្ទាត់ថវិកាត្រូវធ្វើឲ្យមានការបត់បែនច្រើនជាងមុន។[9]

## ៦. ការមើល ឆ្ពោះទៅមុខ

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់តួនាទីនៃការអប់រំ និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការជួយឲ្យប្រទេសកម្ពុជា សម្រេចបាននូវមហិច្ឆតារបស់ខ្លួន ក្នុងការផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលទាបមធ្យមទៅជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ក្នុងឆ្នាំ ២០៣០ និងទៅជាប្រទេសអភិវឌ្ឍន៍នៅត្រឹមឆ្នាំ ២០៥០។ ប្រទេសកម្ពុជាក៏មានគោលបំណងជំរុញសមាហរណកម្មឲ្យកាន់តែស៊ីជម្រៅទៅក្នុងតំបន់(សហគមន៍សេដ្ឋកិច្ចអាស៊ាន៖ASEAN Economic Community- AEC) និងអន្តរជាតិ[11] ហើយសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបួននៃសមាហរណកម្មសហគមន៍សេដ្ឋកិច្ចអាស៊ាន គឺជាលំហូរដោយសេរីនៃពលករជំនាញ។ ដើម្បីអាចទទួលផលប្រយោជន៍ពីសមាហរណកម្មនេះ ការអប់រំនឹងដើរតួយ៉ាងសំខាន់។

របាយការណ៍ស្តីពីភាពប្រកួតប្រជែងជាសកលឆ្នាំ ២០១៦-២០១៧ (The Global Competitiveness Report 2016-2017) បានចាត់ថ្នាក់ប្រទេសសិង្ហបុរីជាប់ចំណាត់ថ្នាក់ទី ២ ក្នុងវិស័យសុខាភិបាល និងអប់រំកម្រិតបឋម ក្នុងចំណោមប្រទេសចំនួន ១៣៨ ហើយប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ១០៣។[12] ប្រទេសសិង្ហបុរី បានជាប់ចំណាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសកំពូលៗនៅលើ កម្មវិធីសម្រាប់ការវាយតម្លៃសមត្ថភាពសិស្សអន្តរជាតិ (PISA) ដែលផ្តល់ចំណាត់ថ្នាក់ផ្នែកអប់រំ ដោយផ្អែកលើការធ្វើការប្រលងជាអន្តរជាតិលើកុមារដែលមានអាយុ ១៥ឆ្នាំ លើមុខវិជ្ជាគណិតវិទ្យា ការអាន និងវិទ្យាសាស្រ្ត។[13] អ្នករៀបចំគោលនយោបាយនៅកម្ពុជា នាពេលបច្ចុប្បន្ននេះ អាចផ្លាស់ប្តូរការយកចិត្តទុកដាក់របស់ខ្លួនដោយផ្តោតទៅលើការលើកកម្ពស់គុណភាពនៃការអប់រំ ក្នុងគោលបំណងបង្កើនការធ្វើសមាហរណកម្មឲ្យកាន់តែ

ជ្រៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងទទួលបានអត្ថប្រយោជន៍បន្ថែមទៀតពីសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។

វាគួរឲ្យកត់សម្គាល់ដែរថា ប្រទេសសិង្ហបុរីមានភាពខុសគ្នាជាច្រើនពីប្រទេសកម្ពុជា។ ប្រទេសសិង្ហបុរី គឺជារដ្ឋទីក្រុងតូចមួយ ហើយមានចំនួនប្រជាជនតិច មានផលិតផលក្នុងស្រុកសរុបខ្ពស់ដូចប្រទេសអភិវឌ្ឍន៍ដែរ ហើយចំណាយថវិកាច្រើនទៅលើវិស័យអប់រំ (សូមមើលតារាងខាងក្រោម) ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាក៏ចាំបាច់ត្រូវកត់សម្គាល់ដែរថា ប្រទេសសិង្ហបុរីបានចាប់ផ្តើមកើតឡើងនៅទសវត្សរ៍ឆ្នាំ ១៩៦០ ជាកោះឯករាជ្យ ក្រីក្រ និងជាកោះដែលមានការអភិវឌ្ឍតិចតួច ដែលអត្រាគ្មានការងារធ្វើខ្ពស់។ ទោះបីជាយ៉ាងណាក៏ដោយ ដោយមានការប្តេជ្ញាចិត្តយ៉ាងរឹងមាំរបស់រដ្ឋាភិបាល និងកំណែទម្រង់វិស័យអប់រំ នៅត្រឹមឆ្នាំ១៩៩៥ សិស្សនៅប្រទេសសិង្ហបុរីបានទទួលលទ្ធផលយ៉ាងល្អពីការប្រលង ″និន្នាការនៃការសិក្សាគណិតវិទ្យាអន្តរជាតិ និងវិទ្យាសាស្ត្រឆ្នាំ ១៩៩៥″ (TIMSS)។ [14]

តារាងខាងក្រោមបង្ហាញពី ព័ត៌មានសំខាន់ៗមួយចំនួនអំពីប្រព័ន្ធអប់រំបច្ចុប្បន្នរបស់សិង្ហបុរី ជាពិសេសទាក់ទងនឹងសាលារៀន គ្រូបង្រៀន កម្មវិធីសិក្សា និងគរុកោសល្យ ដែលអាចជាប្រយោជន៍ដល់ការរកដំណោះស្រាយសម្រាប់កែលម្អគុណភាពនៃការអប់រំនៅកម្ពុជា។

*ព័ត៌មានសម្រាប់ការប្រៀបធៀប*

| សូចនាករ | ប្រទេសកម្ពុជា | ប្រទេសសិង្ហបុរី |
|---|---|---|
| ផលិតផលក្នុងស្រុកសរុប | ២០,០១៧ ពាន់លានដុល្លារសហរដ្ឋអាមេរិក (២០១៦)[15] | ២៩៦,៩៦៦ពាន់លានដុល្លារសហរដ្ឋអាមេរិក (២០១៦)[15] |
| ចំណាយសរុបរបស់រដ្ឋាភិបាល | ៤,៤០៣ ពាន់លានដុល្លារសហរដ្ឋអាមេរិក(២០១៦)[16] | ៧៣,៤៣ ពាន់លានដុល្លារសហរដ្ឋអាមេរិក (២០១៦) |
| ចំណាយលើការអប់រំ | ៩ភាគរយ នៃការចំណាយសរុបរបស់ រដ្ឋាភិបាល (២០១៤)[15] | ២០ភាគរយ នៃការចំណាយសរុបរបស់រដ្ឋាភិបាល (២០១៤)[15] |
| បុគ្គលិកបង្រៀន | កម្រិតបឋមសិក្សា[3]<br>- បញ្ចប់ការសិក្សាមហាវិទ្យាល័យ៖ ៦,៩ ភាគរយ<br>- កម្រិតក្រោមមហាវិទ្យាល័យ៖ ៩៣ ភាគរយ<br>កម្រិតវិទ្យាល័យ<br>- បញ្ចប់ការសិក្សាមហាវិទ្យាល័យ៖ ៣៤,៥២ ភាគរយ<br>- កម្រិតក្រោមមហាវិទ្យាល័យ៖ ៦៥,៤៨ ភាគរយ | កម្រិតបឋមសិក្សា[17]<br>- បញ្ចប់ការសិក្សាមហាវិទ្យាល័យ៖ ៧៤,៦៥ ភាគរយ<br>- កម្រិតក្រោមមហាវិទ្យាល័យ៖ ២៥,៣៥ ភាគរយ<br>កម្រិតវិទ្យាល័យ<br>- បញ្ចប់ការសិក្សាមហាវិទ្យាល័យ៖ ៩៤,៩២ ភាគរយ<br>- កម្រិតក្រោមមហាវិទ្យាល័យ៖ ៥,០៨ ភាគរយ |
| អត្រាគ្រូ និងសិស្ស | កម្រិតបឋមសិក្សា[3]៖ ៤៤,៨<br>វិទ្យាល័យ៖ ១៩,៧ | កម្រិតបឋមសិក្សា (២០១៥)[17]៖ ១៦,០<br>វិទ្យាល័យ (២០១៥)៖ ១២,២ |

| សូចនាករ | ប្រទេសកម្ពុជា | ប្រទេសសិង្ហបុរី |
|---|---|---|
| កម្មវិធីសិក្សា និងគរុកោសល្យ [18] | | • កម្មវិធីសិក្សាបានផ្តោតសំខាន់លើគណិតវិទ្យា វិទ្យាសាស្ត្រ និងជំនាញបច្ចេកទេស<br>• គ្រូបង្រៀនចំណាយពេលវេលាច្រើនក្នុងការរៀបចំមេរៀន ដូច្នេះពួកគេអាចបង្រៀនមេរៀននីមួយៗបានល្អប្រសើរជាងមុនដែលអនុញ្ញាតឲ្យសិស្សអាចរៀនបន្ថែមទៀត។<br>• គោលនយោបាយដែលបានបង្កើតឡើងដោយផ្អែកលើភស្តុតាងពីការស្រាវជ្រាវវិទ្យាសាស្ត្រ។<br>• បន្ថែមលើទិន្នន័យនៅថ្នាក់ជាតិ មន្ត្រីទៅទស្សនកិច្ចសាលារៀនដើម្បីទទួលបានគំនិតល្អៗ អំពីអ្វីដែលកំពុងតែកើតឡើងនៅកម្រិតសាលារៀន។<br>• ធ្វើទស្សនកិច្ចទៅប្រទេសដទៃទៀតដើម្បីស្វែងយល់ និងអនុវត្តតាមបទពិសោធន៍ល្អៗ ទាក់ទងនឹងកម្មវិធីសិក្សា និងគរុកោសល្យ។ ដំណើរការនេះនៅតែបន្ត។ |
| គ្រូបង្រៀន [18] | | • គ្រូបង្រៀនដែលមានគុណភាពខ្ពស់ ត្រូវបានជ្រើសរើសដោយប្រុងប្រយ័ត្ន (អ្នករៀនពូកែនៅក្នុងសាលារៀន)<br>• ប្រាក់ខែដែលទាក់ទាញ គឺត្រូវបានកែតម្រូវជាញឹកញាប់ដើម្បីឲ្យប្រាកដថា ការបង្រៀនត្រូវបានគេមើលឃើញថាមានភាពទាក់ទាញដូចជំនាញ ផ្សេងៗទៀតដែរ។<br>• គ្រូបង្រៀនមានសិទ្ធិទទួលបានការបណ្តុះបណ្តាលជំនាញរយៈពេល ១០០ម៉ោងក្នុងមួយឆ្នាំ ដែលអាចឈានទៅទទួលបានសញ្ញាបត្រកម្រិត វប្បធម៌ខ្ពស់។<br>• ទេពកោសល្យរបស់គ្រូបង្រៀនត្រូវបានកំណត់ និងបានគាំទ្រដោយការអភិវឌ្ឍអាជីព។<br>• ៨៣ ភាគរយនៃគ្រូបង្រៀនបានទទួលការអនុវត្តមុនពេលក្លាយជាគ្រូបង្រៀនពេញម៉ោង។[19]<br>• កម្មវិធីណែនាំសម្រាប់គ្រូបង្រៀនត្រូវបានរៀបចំឡើងសម្រាប់គ្រូស្ទើរតែទាំងអស់ (៩៩ ភាគរយ)។[19]<br>• ក្នុងអំឡុងពេលពីរឆ្នាំដំបូងរបស់គ្រូបង្រៀននៅក្នុងសាលារៀន គ្រូថ្មីត្រូវបានណែនាំ និងដឹកនាំដោយគ្រូបង្ហាត់ដែលមានបទពិសោធន៍ ឬគ្រូបង្រៀនជាន់ខ្ពស់។[19] |
| សាលារៀន | | • អ្នកដឹកនាំដែលមានគុណភាពល្អប្រកបដោយសក្តានុពល និងមានប្រសិទ្ធភាព ត្រូវបានកំណត់ និងបានបណ្តុះបណ្តាល។ ប្រទេសសិង្ហបុរីជឿជាក់ថា អ្នកដឹកនាំល្អ និងដឹកនាំប្រកបប្រសិទ្ធ ភាពអាចនាំឲ្យ |

| សូចនាករ | ប្រទេសកម្ពុជា | ប្រទេសសិង្ហបុរី |
| --- | --- | --- |
| | | មានការបង្រៀនដែលមានគុណភាពល្អ។ យុទ្ធសាស្ត្រ គឺ "ជ្រើសរើស ហើយបង្រៀន" មិនមែន "បង្រៀន ហើយបានជ្រើសរើស នោះទេ" ។[18]<br>• អ្នកដឹកនាំសាលារៀនព្យាយាមបង្កើតបរិយាកាសសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ នាយកសាលាច្រើនជាង៨នាក់ ក្នុងចំណោម១០នាក់ ធានាថា គ្រូបង្រៀនទទួលខុសត្រូវលើការបង្កើនជំនាញបង្រៀនរបស់ពួកគេ និងលទ្ធផលសិក្សារបស់សិស្ស[19]<br>• មានវប្បធម៌នៃការគាំទ្រគ្នាទៅវិញទៅមក និងការគោរពរវាងគ្រូ នឹងគ្រូ។[19]<br>• នាយកសាលាចំនួន ១០០ភាគរយ មានសញ្ញាបត្រសាកលវិទ្យាល័យ[19] |

## ៧. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជា បានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាក់ទងទៅនឹងអត្រាចុះឈ្មោះចូលរៀនសុទ្ធ អត្រាបោះបង់ការសិក្សា អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាទូទៅ ហើយរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការកែលម្អវិស័យអប់រំនៅកម្ពុជាផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអប់រំមូលដ្ឋាននៅតែជួបបញ្ហាទាក់ទងនឹងថវិកាសាលារៀន ការខ្វះខាតគ្រូបង្រៀន (និងគុណភាពគ្រូបង្រៀន) និង ចំណាត់ថ្នាក់ទូទៅនៃការអប់រំ ជាដើម។ល។

បើពិចារណាលើស្ថានភាពបច្ចុប្បន្ននៃវិស័យអប់រំរបស់កម្ពុជា និងចក្ខុវិស័យរបស់រដ្ឋាភិបាល អ្នករៀបចំគោលនយោបាយអាចពិចារណាផ្លាស់ប្តូរការយកចិត្តទុកដាក់ទៅលើការលើកកម្ពស់គុណភាពនៃការអប់រំ ដើម្បីគាំទ្រដល់ចក្ខុវិស័យរយៈពេលវែងរបស់ប្រទេសកម្ពុជា ក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមនៅក្នុងឆ្នាំ ២០៣០ និងប្រទេសអភិវឌ្ឍន៍នៅត្រឹមឆ្នាំ ២០៥០។ បទពិសោធន៍ល្អៗអាចទទួលបានពីការប្រៀបធៀបជាមួយ និងរៀនពី ប្រទេសដទៃ ហើយគួរមានការយកចិត្តទុកដាក់លើបញ្ហាដែលប៉ះពាល់ដល់គ្រូបង្រៀន កម្មវិធីសិក្សា និងសាលារៀន ដែលជាបញ្ហាស្នូលនៅក្នុងវិស័យអប់រំ។

## ឯកសារយោង


1. MoEYS. (2016). *Basic Education* [Online]. Online MoEYS. Available: http://www.moeys.gov.kh/en/primary-education.html#.WV6HVcaB3dc.
2. UNICEF Education.
3. Department of Education Management Information System (2016). Education Statistics and Indicators *In:* DEPARTMENT OF EDUCATION MANAGEMENT INFORMATION SYSTEM (ed.).
4. Ministry of Education, Y. a. S. (2017). Education Congress: The Education, Youth and Sport Performance in the Academic Year 2015-2016. Phnom Penh, Cambodia
5. Ministry of Education, Y. a. S. (2012). Guideline on the Establishment and Functioning of Primary School Support Committee *In:* MINISTRY OF EDUCATION, Y. A. S. (ed.) *No. 30 AYK.SCN.*
6. ANU Enterprise (2011). Gender Responsive Decentralized Governance in Asia: A Study of Cambodia
7. Vanda, V. (2015). Meeting Basic Learning Needs through Primary Education. *In:* SOTHY, K., MADHUR, S. & RETHY, C. (eds.) *Cambodia Education 2015: Employment and Empowerment.* Phnom Penh, Cambodia Cambodia Development Resource Institute.
8. Phin, C. (2014). Challenges of Cambodian Teachers in Contributing to Human and Social Development: Are They Well-Trained? *International Journal of Social Science and Humanity,* 4.
9. Naron, H. C. (2016). *Education Sector Reforms in Cambodia,* Phnom Penh, Cambodia
10. Romina de Jong, L. T., Gordon Conochie (2013). Primary School Budgets in Cambodia: a Public Expenditure Tracking Survey. NGO Education Partnership (NEP).
11. RGC (2015). Rectangular Strategy Phase III, . Phnom Penh, Cambodia Royal Government of Cambodia
12. World Economic Forum (2017). The Global Competitiveness Report 2016-2017. Switzerland
13. OECD (2016). PISA 2015 Results in Focus.
14. (OECD), T. O. f. E. C.-o. a. D. (2015). PISA 2015 high performers: Singapore
15. World Bank Data (2017). World Bank Open Data.
16. (2015). Budget Law 2016. Cambodia
17. Ministry of Education (2016). Education Statistics Digest 2016. Singapore
18. The Organisation for Economic Co-operation and Development (2010). Singapore: Rapid Improvement Followed by Strong Performance.
19. The Organisation for Economic Co-operation and Development (OECD) (2013). Results from TALIS 2013: Singapore.